# ដំណាំស្ពៃក្ដោប

## I. ស្ថានភាពទូទៅ



ស្ពៃក្ដោបជាដំណាំមួយប្រភេទ ដែល មានប្រភពពីកំណើតមកពីទ្វីបអឺរ៉ុប ។ ជាយូរយារកន្លងមកដំណាំនេះត្រូវបាន គេដាំនៅក្នុងតំបន់អឺរ៉ុបប៉ែកខាងកើតនិងតំបន់មួយចំនួនក្នុង ទ្វីបអាហ្វ្រិក ។ ក្រោយមកដោយវិទ្យាសាស្ត្របង្កាត់ ពូជជឿនលឿនគេបានបង្កាត់ពូជតំរូវ ទៅតាមតំបន់ដាំដុះដំណាំប្រភេទនេះស្ថិតនៅក្នុងគ្រួសារ Gruciferaeក្នុងអំបូរBrassica Oleracea ។ ស្ពៃក្ដោបជាទូទៅចែកចេញជា ៣ ប្រភេទទៅតាមពណ៌នៃស្លឹក:

-ពូជស្លឹកពណ៌ស្វាយ

-ពូជស្លឹកពណ៌ស

-ពូជស្លឹកពណ៌ក្រហម

ការនិយមដាំនៅប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ គឺពូជឈ្មោះ KK Gross ផលិតដោយក្រុមហ៊ុន Takiiseed Company ។ នៅពេលថ្មីៗនេះនៅប្រទេសភីលីពីន។



គេនិយមដាំពូជឈ្មោះ Rareball ដែលផលិត ដោយក្រុមហ៊ុន Kaneco Seed Company នៃប្រទេសជប៉ុន ។ គ្រាប់ពូជមានភាពល្អិតៗ ទំងន់ ១ក្រាមមាន ចំនួន ២០០-៣០០ គ្រាប់ ដើម្បីដាំ១ហាត គេប្រើគ្រាប់ពូជចំនួន៣៥០-៤០០ ក្រាម ។

## II. បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសរដូវ

ការជ្រើសរើសរដូវមានសារៈសំខាន់នៅក្នុងការដាំដុះដំណាំ ។ រដូវទាក់ទងនឹង សីតុណ្ហភាព ភ្លៀង សំណើម បរិយាកាស ជំងឺ និង សត្វល្អិត។ ដំណាំស្ពៃក្ដោបគេច្រើន តែដាំនៅរដូវត្រជាក់ ។ នៅប្រទេសកម្ពុជាយើងគេអនុវត្តន៍ពីខែតុលា ដល់ខែកុម្ភៈ ចន្លោះពេលនេះគឺសីតុណ្ហភាពត្រជាក់ ពន្លឺថ្ងៃ និង ចំណាំងរបស់ពន្លឺសមស្រប សត្វល្អិត និង ជំងឺមិនមានការរាតត្បាតខ្លាំង។ ចំពោះពូជឈ្មោះ KK Cross មកពីជប៉ុន រដូវនេះសមស្របល្អជាងពូជឯទៀតៗ។

### ២-ការជ្រើសរើស និងរៀបចំដី

ដំណាំស្ពៃក្ដោបជាប្រភេទដំណាំមួយត្រូវការដុះលូតលាស់លើប្រភេទដីធូរស្រទាប់ ដាំដុះជ្រៅសំបូរទៅដោយជាតិមមោកព្រមទាំងសំបូរទៅដោយ សារធាតុចិញ្ចឹមផ្សេងៗទៀត ។ ដំណាំនេះគេរាប់បញ្ចូលទៅក្នុងក្រុមមិនធុនទ្រាំនឹងដីអាស៊ីដគេរៀបចំដីដោយប្រើត្រាក់ទ័រគោយន្ត ឬដោយនង្គ័លគោ មុននឹងភ្ជួរគេរាស់ទុកដីឱ្យស្ងួតស្រស់ទឹក ហើយប្រមូលយកស្មៅ ឬកាកសំណល់ចេញពីដីឱ្យស្អាត ទើបគេភ្ជួរលើកដំបូងក្រោយ។

ពីភ្ជួរហើយគេត្រូវហាលដីនោះរយៈពេល ២ទៅ៣ថ្ងៃ រាស់បំបែកដីឱ្យល្អិត ទើបភ្ជួរ ប្រែដី លើកទី២ ក្រោយពីភ្ជួរហើយ ត្រូវហាលដីនោះ ឱ្យស្ងួតល្អ ដើម្បីឱ្យស្មៅ ឬ សត្វល្អិតចង្រៃងាប់ ប៉ុន្តែចំពោះដី ដែលកង្វះជាតិកំបោរ គេបាចកំបោរចំនួន ២៥០ ទៅ៣៥០ គ.ក្រ/ហ.ត ហើយរាស់លប់ទៅក្នុងដី។ គេភ្ជួរនឹងរាស់ចំនួន ២-៣ លើកឱ្យ បានជ្រៅ និងឱ្យល្អិតធានាឱ្យមានបន្ទុកខ្យល់គ្រប់គ្រាន់ និងឱ្យទឹកជ្រាបបានល្អរក្សាសំណើមដីបានយូរ។ ជាទូទៅការរៀបចំដីសំរាប់ដំណាំបន្លែ គឺដីស្ងួត និងមានប្រភពគ្រប់គ្រាន់ដើម្បីស្រោចស្រព ។







៣-ការបណ្តុះកូន

ដើម្បីធានាឱ្យកូនស្ពៃក្តោបដុះលូតលាស់ល្អគ្មានជំងឺ និងសត្វល្អិតបំផ្លាញ គេគួរតែជ្រើសរើសកន្លែង សំរាប់សាបកូនដែលមានលក្ខខណ្ឌដូចតទៅ ។ ដីមាន ជីជាតិ នៅក្បែរប្រភពទឹកឃ្លាតឆ្ងាយពីចំការ ស្ពៃឯទៀត វាលស្រឡះមានពន្លឺគ្រប់គ្រាន់ ។ គេត្រូវភ្ជួរ ឬរៀបដីនោះឱ្យផុសល្អរើសយកស្មៅចេញហាល ដីឱ្យស្ងួត វាយបំបែក ដីឱ្យម៉ត់ល្អ ហើយបាចកំបោរសចំនួន ២៥០ក្រាម លើផ្ទៃដី ២០ម$^{២}$ ក្រោយមក លើករងឱ្យបានខ្ពស់គឺទទឹង ១ម បណ្តោយ ១០ម កំពស់ពី ១៥-២០ សម ត្រូវយកជី ១៥.១៥.១៥ ចំនួន ១៥០ ក្រាម ទៅបាចពីលើ ហើយរាស់លប់ជីនោះឱ្យ។

កប់ទៅក្នុងដី (ហាមប្រើជីលាមកសត្វ មិនទាន់ពុក ) ក្រោយមកទៀតយកថ្នាំប្រភេទ Furadan ២០ ក្រាម និងប្រភេទថ្នាំផ្សិតឈ្មោះ Mancozeb ឬ Orthocide ចំនួន ១៥ ក្រាម ទៅបាចលើថ្នាលនោះ ទើបគេសាបគ្រាប់ស្ពៃទៅក្នុងថ្នាល ដោយប្រើទំងន់ គ្រាប់ចំនួន ៧-១០ក្រាមលើផ្ទៃដី១០ម២ដើម្បីដាំលើផ្ទៃដី ១ ហ.ត គេត្រូវប្រើគ្រាប់ពូជចំនួន ៣០០-៣៥០ក្រាម ។ ក្រោយពីសាបហើយត្រូវយកកំទេចចំបើងស្ងួតកាត់ ឱ្យខ្លីៗបាចពីលើឱ្យក្រាស់ហើយស្រោចឱ្យជោគ ហើយគ្របសំណាញ់ពណ៌ខ្មៅក្រឡាញឹកឱ្យជិត ការពារកុំឱ្យពពួកសត្វល្អិតចូលបំផ្លាញ ដើម្បីឱ្យកូនស្ពៃដុះល្អគេចាប់ផ្តើមដក ស្មៅនិងដករំលស់កូនស្ពៃចេញឱ្យរង្វើល ក្រោយពីសាបរយៈ ពេល ៨-១០ថ្ងៃ ហើយ ស្រោចបំប៉នជី Urea ៤៦% ដោយប្រើកំរិត ១ស្លាបព្រាបាយ លាយទឹក ២០លីត្រ ឱ្យជោគហើយស្រោចទឹកធម្មតាតាមក្រោយ។ ក្រោយមកទៀតកូនស្ពៃអាយុ ១៨-២០ ថ្ងៃ គេស្រោចជីបំប៉នដោយប្រើប្រភេទ ៤៦% ដដែលកំរិត១ ស្លាបព្រាយ Urea (១០-១៥ក្រាម) លាយទឹក ១៥-២០លីត្រ ស្រោចឱ្យជោគ និងស្រោចទឹកធម្មតា តាមក្រោយ ។ អនុវត្តតាមវិធីនេះរយៈពេល ២៥-២៨ ថ្ងៃ គេអាចដកកូនស្ពៃយកទៅដាំ ប៉ុន្តែមុននឹងយកទៅរយៈពេល ២ថ្ងៃ គេផ្អាកការស្រោចទឹកឱ្យកូនស្ពៃធន់ទ្រាំ និងការកង្វះទឹក និងកំដៅថ្ងៃដល់ពេលរៀបដកត្រូវស្រោចទឹកឱ្យជោគទើបគេដក កូនយកទៅដាំ គឺវាមានសន្លឹក៣-៤ កំពស់ ៨-១០សម។ ចំពោះវិធីផ្សាំកូនវិញគេ ដកកូនស្ពៃមានអាយុ ១៤-១៦ថ្ងៃ មានសន្លឹក២ គឺគេផ្សាំក្នុងកន្ទោង ឬស្បោង ដោយក្នុងនោះមានលាយជីផេះអង្កាម និងជីធម្មជាតិផុសល្អក្រោយពីផ្សាំក្នុងកន្ទោង ហើយស្រោចទឹកជោគ និងគ្របពេលថ្ងៃ រយៈពេល ២ថ្ងៃ ទើបលែង គ្រប គឺបើកចំហ



ទាំងយប់ ទាំងថ្ងៃលើកលែងតែពេលភ្លៀង ទើបគ្របគំរប ការពារពីលើ ។ ក្រោយពី ផ្សាំរយៈពេល ១០-១២ថ្ងៃ អាចដាំបាន ។

៤- ការដាំដុះស្ពៃក្តោប

ដើម្បីការដាំដុះដំណាំស្ពៃក្តោបបានល្អ ដំបូងត្រូវលើករងជាមុនសិន។ គេលើក រងឱ្យបានកំពស់ ពី ១៥-២០ស.ម ទទឹង ១០០ស.ម បណ្តោយ ១០-១៥ម ក្នុងករណីដីមានជំរាល គេគួរតែលើករងទទឹងជំរាលរបស់ដីក្រោយមកទៀតគេរាស់ដោយរនាស់ដៃយកស្មៅចេញ និងពង្រាបរងស្មើល្អ ទើបគេកាប់រណ្តៅនៅលើរងជា២ជួរ ចន្លោះ ។



ជួរ ៧០សម ន្លោះរណ្ដៅគឺ ៥០-៦០សម បន្ទាប់មកយកជីគីមីប្រភេទ ១៥.១៥.១៥ ឬ (១៨ . ៤៦ . ០ )ចំនួន ២០០គក្រ ជីលាមកសត្វ ឬកំប៉ុស្ដិ៍ចំនួន ១៥-២០តោន និង រោយថ្នាំប្រភេទ Furadan ចំនួន ១០ គ.ក្រ ក្នុងផ្ទៃដី ១ហ.ត ហើយជ្រំលាយ បញ្ចូលគ្នាទើប យកកូនមកដាំ ។ កូនស្ពៃក្ដោបមុននឹងយកទៅដាំត្រូវស្រោចទឹក ឱ្យជោគជាមុន ១គុម្ព ១ដើម គេដាំនៅពេលថ្ងៃរសៀល ដាំហើយភ្លាមត្រូវស្រោច ទឹកឱ្យជោគ។ គេបន្តការស្រោចទឹកក្នុង១ថ្ងៃ ៣ លើក ព្រឹក ថ្ងៃត្រង់ និងល្ងាចរ យៈពេល ២ថ្ងៃ ។

**៥-ការស្រោចស្រព**





ដំណាំអំបូរស្ពៃត្រូវការទឹកជាប្រចាំប៉ុន្តែវាមិនត្រូវការសំណើមដីខ្ពស់ពេកនោះទេ ជាមធ្យមចន្លោះពី ៨០-៨៥% មធ្យមប្រចាំថ្ងៃ ។ គេស្រោចទឹកបានច្រើនវិធី គឺ ស្រោចដោយប៉ោត ព្រឹក និងល្ងាច លើផ្ទៃដី ១៥ម$^{២}$ ក្នុង១ ថ្ងៃ ជាមធ្យមពី ៧០-៨០ លីត្រ ។ ចំពោះការស្រោចដោយឧបករណ៍ម៉ាស៊ីនទំនើប ១ ថ្ងៃ គេបាញ់ម្ដង ជា ពិសេសនៅពេលល្ងាចជាការល្អ ។ ចំពោះការស្រោចដោយបញ្ចូលផ្ទាល់គេ ធ្វើឡើងលើប្រភេទដីរាបស្មើ និង ដំណាក់កាលស្ពៃក្ដោបរួចហើយ។ ដំណាំនេះ ត្រូវការទឹកខ្លាំងក្នុងដំណាក់កាលក្រោយដាំ៤៥-៥០ថ្ងៃ ។

**៦-ការជ្រំជ្រួយដី**



ការជ្រំជ្រួយដីពូនគល់ មានគោលបំណងយ៉ាងសំខាន់ គឺ ធ្វើឱ្យដីធូរខ្យល់ ចេញចូលព្រមទាំងរក្សាសំណើមបានយូរ ការជ្រាបទឹកបានរហ័សបន្ថយការដុះស្មៅ ។ មុនពេលជ្រំដីគេត្រូវផ្អាកការស្រោចទឹកចំនួន ១ថ្ងៃមុន ហើយជ្រំជ្រួយដីឱ្យផុស និងបន្ទាប់មកហាលដីនោះមួយថ្ងៃទៀត ដើម្បីឱ្យស្មៅងាប់ក្រោយមកទើបគេស្រោចទឹកអោយជោគខ្លាំង។ ការជ្រំជ្រួយដីគេធ្វើឡើងជា ២លើក គឺលើកទី ១ ចំនួន ១០-១៥ថ្ងៃ ក្រោយដាំនិងលើកទី២ គឺ ៣៥-៤០ថ្ងៃក្រោយដាំ ក្រោយមកទៀត គេមិនជ្រំជ្រួយដីឡើយគឺគ្រាន់តែសំអាតស្មៅប៉ុណ្ណោះការពារការដាច់ឫសរបស់ស្ពៃធ្វើឱ្យស្ពៃពន្យារពេលក្តោប ។

**៧-ការប្រើប្រាស់ជី**





ដំណាំស្ពៃក្តោបត្រូវការជីយ៉ាងខ្លាំងជាងដំណាំស្ពៃងទៀត ។ ក្នុងដំណាក់កាលនៅតូចវាត្រូវការធាតុអាសូត (N)ច្រើនដើម្បីដុះលូតលាស់ទំហំស្លឹក និងចំនួនស្លឹកព្រមទាំងពន្លូតដើមពិសេសគឺដំណាំមានពណ៌បៃតងខ្ចី ។ ចំពោះធាតុ ផូស្វរ័ (P) ដំណាំ ត្រូវការជាបណ្តើរៗចាប់តាំងពីដាំ រហូតដល់ប្រមូលផល គឺធ្វើឱ្យស្លឹកក្រាស់ ដើមធំ រឹងមាំ ពង្រីកប្រពន្ធ័ឫស ឱ្យរឹតតែសកម្មដើម្បីការដឹកជញ្ជូនសារធាតុទឹក និងរ៉ែផ្សេងៗ ។

- មុនពេលដាំគឺទ្រាប់បាត Basal ជីធម្មជាតិ និង១៥-២៥តោន ជី ១៥.១៥.១៥ ចំនួន ២០០ គ.ក្រ/ហ.ត

- ក្រោយពីដាំរយៈពេល ៥ - ៧ ថ្ងៃ គេស្រោចជីអ៊ុយរ៉េ ៤៦ % ចំនួន ៤០ គក្រ ដោយលាយជាមួយទឹកស្រោចជុំវិញ គល់ហើយស្រោចទឹកលាងតាមក្រោយជាធម្មតា។

- ក្រោយពេលដាំរយៈពេល ១៨-២០ថ្ងៃ គេប្រើជី ១៥.១៥.១៥ ចំនួន ២០០ គ.ក្រ លាយជាមួយជីអ៊ុយរ៉េ ៤៦% ចំនួន៧០-៨០គក្រ និងជី Potasium ៦០% ចំនួន១០០គក្រ លាយជាមួយគ្នាហើយដាក់នៅតាមចន្លោះគុម្ព នឹងលុបដីឱ្យជិតហើយស្រោច ទឹកឱ្យជោគ ។

- ក្រោយដាំរយៈពេល ៣០-៣៥ ថ្ងៃ ត្រូវដាក់ជីបំប៉នប្រភេទអ៊ុយរ៉េ ៤៦% ចំនួន ៥០-៦០គក្រ ក្នុង ១ហាត ដោយលាយទឹកស្រោចឬដាក់តាមចន្លោះគុម្ពក្រោម ស្លឹកស្រោច ឬបញ្ជូលទឹកភ្លាម ។

- ក្រោយដាំរយៈពេ ៤៥-៥០ ថ្ងៃ ត្រូវដាក់ជីជាលើកចុងក្រោយ

ដោយប្រើប្រភេទជី ១៥.១៥.១៥ ចំនួន ១០០គ.ក្រ លាយជាមួយជីអ៊ុយរ៉េ ៤៦% ចំនួន ៨០គ.ក្រ និងជីប៉ូតាស្យូមចំនួន ៥០គ.ក្រ ហើយដាក់តាមចន្លោះជួរស្ពៃ បន្ទាប់មកស្រោចឬ បញ្ចូលទឹកភ្លាម ។

## III. ជំងឺ និងវិធានការការពារ

### ១-អំពីជំងឺសំខាន់ៗ

- ជំងឺពកឫស: ជាទូទៅគេប្រទះឃើញជំងឺនេះតែងតែកើតនៅលើឫសធ្វើឱ្យពកនិងរួញ ស្លឹកពណ៌លឿងផ្នែកខាងក្រោម ហើយទុំជ្រុះស្លឹកក្នុងដំណាក់កាលស្ពៃក្តោប និងកំពុងក្តោប ជំងឺនេះរីករាលដាលពីដើម១ទៅដើម១ ដោយសារទឹកយ៉ាងឆាប់រហ័ស វាស្ថិតនៅក្នុងក្រុមជំងឺផ្សិត គេដកដើមនោះចេញហើយជ្រំដីហាលឱ្យស្ងួត គ្រង់កន្លែងកើត និងបាចកំបោរទុកចោល ។

- ជំងឺរលួយឫស: ធ្វើឱ្យលឿងស្លឹកក្រោយមកដើមទាំងនោះស្រពោនក្រោយ មកឫសឡើងទន់រលួយប្រែពណ៌ទៅជាខ្មៅ ស្ពៃក្តោបមិនអាចលូតលាស់បានឡើយវា បំផ្លាញគ្រប់ដំណាក់កាលលូតលាស់។ក្រៅពីនេះនៅមានជំងឺជាច្រើនទៀតនៅក្នុងក្រុម ជំងឺផ្សិតដូចជា Altermaria leaf spot/ Downy Mildew spot,White mold តែងតែ បំផ្លាញគ្រប់ដំណាក់កាលលូតលាស់ ។

- ក្រុមជំងឺបាក់តេរី Bacterial Diseases មានជំងឺ Soft rot, Black rot បណ្តាលមកពីមេរោគ Xanthomonas ភាគច្រើនធ្វើឱ្យរលួយបណ្តូលស្ពៃ និងរលាកក្នុងរលា





ក្តោបតាមស្រទាប់ៗ ហើយទន់។

- ក្រុមវីរុស ធ្វើឱ្យរួញស្លឹកលែងលូតលាស់ វាបណ្តាលមកពីពួកចៃរោមបំផ្លាញ ។

**២- វិធានការការពារ និងកំចាត់ជំងឺ** ជំងឺផ្សិត៖ បន្ថយការស្រោចទឹកនិងស្រោចទឹកនិងស្រោចជីអាសូត ទុកដីឱ្យស្ងួតដកស្មៅអោយស្អាតបាចកំបោរគ្រង់កន្លែងកើត និងយកថ្នាំផ្សិត ដូចជាOrthocide/ Zineb/ Mancozeb ចំនួន ២០ក្រាម លាយទឹក ១៥លីត្រ បាញ់ការពារនៅពេលឃើញមានសញ្ញាលើស្លឹកមុនពេលជំងឺនេះរីករាលដាល។

ការប្រើប្រាស់ថ្នាំប្រភេទដូចជា B.T គឺ Bacilus Thuringiensis មាន zondor vita-gro, Dielfin, Bacillus ដោយលាយជាមួយ និងថ្នាំគីមីពុលដូចជា Sumicidine, Sum-ithion, Me ប្រើកំរិត ១,៥ លីត្រ - ២លីត្រ/ហាត Viphos Pegasuss Atobron Vertimex។

**២- ដង្កូវហ្វូងឈ្មោះ** Spodoptera SP វាតែងតែស៊ីបំផ្លាញដំណាំស្ពៃក្តោប គ្រប់ដំណាក់កាលលូតលាស់ធ្វើឱ្យស្ពៃក្តោបត្រូវខូចខាតទាំងស្រុង ។ លក្ខណៈ







ជំងឺបាក់តេរីៈ បន្ថយការស្រោចទឹក ដកដើមកើតជំងឺចេញ ប្តូរមុខដំណាំផ្លាការ ដុះដុតសំលាប់មេរោគដីថ្នាលបណ្តុះ ។

- ក្រុមជំងឺវីរុសៈ បាញ់ថ្នាំសំលាប់ពួកចៃ មមាច និង ទ្រីព និងដកដើមទាំងនោះចោល និង ជ្រើសរើសពូជធន់ ។

## IV. **អំពីសត្វល្អិតចង្រៃ និង ការការពារ**

**១- ដង្កូវយោលទោងៈ** ដង្កូវប្រភេទនេះតែងតែបំផ្លាញលើប្រភេទដំណាំអំបូរស្ពៃគ្រប់ប្រភេទវាមានអាយុកាលខ្លីពីពងរហូតដល់មេអំបៅ ចំនួនតែ ១២-១៦ថ្ងៃ ប៉ុណ្ណោះស៊ីបកជាលិការុក្ខជាតិពីផ្នែកខាងក្រោមធ្វើឱ្យស្ពៃក្តោបលែងដុះលូតលាស់បាន ។ ដើម្បីការពារដង្កូវប្រភេទនេះគឺគេចាប់ផ្តើមដាំនៅចុងរដូវភ្លៀងពិសេសពីខែ ១០-១១ ដើម្បីឱ្យស្ពៃក្តោបជាប់ ក្នុងខែ ១២ ជារដូវដែលដង្កូវយោលទោងបំផ្លាញមិនធ្ងន់ធ្ងរ ។ ម្យ៉ាងទៀតគេសាបកូនស្ពៃនៅក្នុងផ្ទះសំណាញ់ការពារកូនស្ពៃមិនឱ្យ មានដង្កូវនេះចូលស៊ី ធ្វើឱ្យស្ពៃអាចលូតលាស់លឿន ។ ចំពោះកម្មវិធី IPM គេចិញ្ចឹម សត្វមានប្រយោជន៍ឱ្យតាមកំចាត់ដង្កូវយោលទោងតាមប្រពន្ធ័ Biology Cal Control គឺសត្វឈ្មោះ Cotesia Plutellae និង Microplits Plutellae សត្វឱម៉ាល់ពីរប្រភេទនេះ តែងតែត្រូវការដង្កូវយោលទោងដើម្បីបង្កើតកូនចៅរបស់វា ។

ការសំអាតស្មៅ ជ្រើសរើសរដូវដាំលាយជាមួយ ដំណាំឯទៀត ការប្រើប្រាស់ពូជធន់ ជាវិធានការដែលអាចជ្រើសយកបាន វិធានការណ៍ ចុងក្រោយគឺណែន ។ គេកាត់ដោយរក្សាសន្លឹកខៀវ ពទ្ធ័ជុំវិញក្តោបចំនួន ៣-៤ សន្លឹក ដើម្បី

ពិសេសរបស់វាគឺវាញាស់ទាំងហ្វូងៗ ចាប់ពីពងទៅដល់ មេអំបៅមានអាយុ ៤២ ថ្ងៃ ការ កំចាត់មានប្រសិទ្ធិភាពគឺពេលវាទើបញាស់ ។

**៣- ដង្កូវស៊ីកំពូលស្ពៃឈ្មោះ** Cabbage Webworm វាស៊ីតែកំពូលខ្ចីៗ ។

**៤- សត្វទាគូ** Striped flea beetle leaf វាស៊ីដោយចាក់ទំលុះស្លឹក ឱ្យធ្លុះ ទុះៗ ពេលវាទើបនឹង ញាស់នៅក្នុងដីកូនដង្កូវរបស់វាតែងស៊ីឫសស្ពៃ ធ្វើឱ្យស្ពៃ ញោម ស្រពោន គេបាចមុនពេលដាំ ឬក្រោយដាំរយៈ ពេលមួយអាទិត្យឈ្មោះថ្នាំ Furadun ៣$^{H}$ និង ៥$^{H}$ កំចាត់ដង្កូវរបស់វានៅតូចៗ ។ ក្រៅពីនោះគេបាញ់ថ្នាំដូចជា ដង្កូវយោលទោងដែរតែមិនបាញ់ថ្នាំប្រភេទBTទៅលើដង្កូវ Spodoptera Cabbage Webworm ឬFleabeetleទេ ។

**ការកំចាត់តាមវិធីសាស្ត្រ ក្សេត្រសាស្ត្រ** ៖អាចជួយឱ្យការដាំដុះលូតលាស់បានល្អប្រសើរ ។

## V. ការប្រមូលផល

ការប្រមូលផល ត្រូវធ្វើឡើងទៅតាមប្រភេទពូជ ពូជធ្ងន់មានអាយុកាលពី ៩០-១១០ថ្ងៃ ក្រោយដាំពូជកណ្តាលគឺ ៨០-៩០ថ្ងៃ ពូជស្រាលពី ៦៥-៧០ថ្ងៃ ប៉ុន្តែការដាំនៅប្រទេសកម្ពុជា សមស្របគឺពូជ៨០-៩០ថ្ងៃ គឺពូជ KK Cross និង Rareball មុនពេលប្រមូលផលគេផ្អាកការស្រោចទឹករយៈពេល ៥-៧ថ្ងៃ ដើម្បីស្ពៃក្តោបរឹត៕



រក្សាទុកបានយូរ និងធានាការដឹកជញ្ជូនទៅកាន់ទីឆ្ងាយៗនៅ ប្រទេសកម្ពុជាទិន្នផលមធ្យម ចន្លោះពី ២៥-៣០ តោន/ហ.ត ។



